ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.ធ៩.១៣-០១៨-៤៣៣៣.ស.ឃ៣

ថ្ងៃចន្ទ ១២ កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១៨

## សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ លើកទី៤៤

នៅថ្ងៃសុក្រ ៩រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង ៨:៣០ នាទីព្រឹក ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី៤៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ទេសាភិបាល និងជាប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ។ អង្គប្រជុំបានពិភាក្សាលើរបាយការណ៍ស្តីពី ស្ថានភាពអតិផរណាប្រចាំត្រីមាសទី២ ឆ្នាំ២០១៨ និងបានសម្រេចលើជម្រើសការអនុវត្តគោលនយោបាយរូបិយវត្ថុចម្បងៗសម្រាប់ឆ្នាំ២០១៨ ដូចខាងក្រោម ៖

១/- បន្តប្រកាន់យករបបអត្រាប្តូរប្រាក់ដែលមានស្ថិរភាពដោយធ្វើអន្តរាគមន៍ចាំបាច់ផ្អែកលើការប្រែប្រួលនៃសេដ្ឋកិច្ច ដើម្បីបន្តពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល

២/- បន្តធ្វើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ក្នុងអត្រាការប្រាក់សមស្រប ដើម្បីផ្តល់សន្ទនីយភាពទៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងរួមចំណែកអភិវឌ្ឍទីផ្សារអន្តរធនាគារ និង

៣/- បង្កើនការយល់ដឹងរបស់សាធារណជនពីសារៈសំខាន់និងតួនាទីប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចនិងសង្គម ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ។

ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
ប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ

ជា-ចាន់តូ

ចម្លងជូន ៖
- សមាជិកគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ
- ឯកសារ-កាលប្បវត្តិ

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧